**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

# សេចក្តីថ្លែងការណ៍
# របស់
# ឯកឧត្តមទេសរដ្ឋមន្ត្រី ប្រាក់ សុខុន
# រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

ក្នុងឱកាសកិច្ចពិភាក្សាទូទៅនៃមហាសន្និបាត

អង្គការសហប្រជាជាតិលើកទី ៧២

ញូវយ៉ក ថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ២០១៧

ឯកឧត្តមប្រធានអង្គមហាសន្និបាត

ឯកឧត្តម លោកជំទាវ និងអស់លោក លោកស្រី

១. តាងនាមរាជរដ្ឋាភិបាលកម្ពុជា និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ ខ្ញុំសូមសំដែងនូវការអបអរសាទរចំពោះឯកឧត្តម Miroslav Lajčák ដែលជាប់ឆ្នោតជាប្រធាននៃមហាសន្និបាតអង្គការសហប្រជាជាតិលើកទី ៧២ ។ ខ្ញុំក៏សូមឆ្លៀតឱកាសនេះសំដែងនូវអំណរគុណចំពោះឯកឧត្តមប្រធាន Peter Thomson នៃប្រទេសហ្វីជី ចំពោះកិច្ចខិតខំប្រឹងប្រែងបំពេញភារកិច្ចរបស់ឯកឧត្តមក្នុងអាណត្តិអង្គមហាសន្និបាទកន្លងទៅ។ ខ្ញុំសូមចូលរួមជាមួយនឹងវាគ្មិនខាងដើមទាំងឡាយ ក្នុងការសម្តែងនូវមរណទុក្ខ និងសមានចិត្តដ៏ជ្រាលជ្រៅបំផុតចំពោះជនរងគ្រោះដោយការរញ្ជួយដីនៅប្រទេសម៉ិចស៊ីកូ ព្រមទាំងក្រុមគ្រួសាររបស់ពួកគេ ។

២. គណៈប្រតិភូយើងខ្ញុំវាយតំលៃថា មូលបទនៃមហាសន្និបាតឆ្នាំនេះមានភាពប្រទាក់ក្រឡា និងក្តោបបានយ៉ាងពេញលេញទៅលើអាទិភាពទាំង ៦ របស់ឯកឧត្តមប្រធានដែលឆ្លើយតបទៅនឹងនិន្នាការសកលដែលពិភពលោកយើងកំពុងជួបប្រទះ។ អន្តរកម្មរវាងកំណើនប្រជាជន ចរន្តទេសន្តរប្រវេសន៍ បម្រែបម្រួលអាកាសធាតុ និងអសន្តិសុខស្បៀងកាន់តែធ្វើអោយចរន្តសកលនេះមានសភាពគួរអោយព្រួយបារម្ភថែមទៀត។

៣. ដូចគ្នាដែរ កម្លាំងនៃសាកលភាវូបនីយកម្មដែលបានបង្កើនភាពពឹងពាក់គ្នាទៅវិញទៅមក ក៏បាននិងកំពុងចាប់ផ្តើមបង្ហាញនូវភាពចន្លោះប្រហោងនៃសណ្តាប់ធ្នាប់សកលបច្ចុប្បន្ន។ ជាង២៥ឆ្នាំក្រោយការបញ្ចប់នៃសង្គ្រាមត្រជាក់ ពិភពលោកកាន់តែមានភាពស្មុគស្មាញ និងមានភាពប្រឈមធ្ងន់ធ្ងរជាងអតីតកាល ។ បច្ចុប្បន្ននេះ ពិភពលោកពហុប៉ូលរបស់យើងបានបង្ហាញរូបរាងកាន់តែច្បាស់នៅក្នុងកិច្ចការអន្តរជាតិ ហើយបាន បង្កើតនូវភាពចលាចល និងវឹកវរដោយសារតែការប្រកួតប្រជែងអំណាចរវាងប្រទេសមហាអំណាចកាន់តែមានភាពស្រួចស្រាវឡើង ។ យើងកាន់តែពឹងពាក់គ្នាទៅវិញទៅមក ប៉ុន្តែ ទន្ទឹមនឹងនេះ វិសមភាពក៏មានការកើនឡើងដែរ ។ យើងមានវិបុលភាពជាងមុន ប៉ុន្តែ ទន្ទឹមនឹងនេះ ប្រជាជនរាប់លាននាក់នៅតែប្រឈមមុខនឹងភាពក្រីក្រ ។ កត្តាទាំងអស់នេះហើយដែលបញ្ជាក់ថា ពិភពលោកបាត់តុល្យភាព ហើយនេះគឺជាវិសមិតភាពដែលកំណត់ពិភពលោកយើងបច្ចុប្បន្ន ។

៤. ទន្ទឹមនឹងការសម្តែងនូវក្តីព្រួយបារម្ភយ៉ាងជ្រាលជ្រៅចំពោះសភាពការណ៍នៅឧបទ្វីបកូរ៉េ យើងសូមអំពាវនាវដល់គ្រប់ភាគីពាក់ព័ន្ធទាំងអស់អោយរក្សាភាពអត់ធ្មត់ខ្ពស់បំផុត ដើម្បីចៀសវាងនូវសកម្មភាពបង្កហេតុ និងសូមបន្តប្តេជ្ញាចូលរួមក្នុងកិច្ចសន្ទនាដោយសន្តិភាព និងលក្ខណៈស្ថាបនា ដើម្បីបន្ធូរបន្ថយភាពតានតឹង និងជម្រុញការទុកចិត្ត និងភាពជឿជាក់នៅក្នុងតំបន់ ។ កត្តាមួយទៀតដែលធ្វើអោយសន្តិសុខ

សមូហភាពមានភាពរង្គោះរង្គើដែរនោះ គឺការដាក់ទណ្ឌកម្មជាឯកតោភាគី និងដោយខុសច្បាប់ចំពោះប្រទេសគុយបា ។ យើងអំពាវនាវអោយបញ្ឈប់នូវការរំលោភបំពានច្បាប់អន្តរជាតិនេះ។

៥. ឯកឧត្តមប្រធាន ពិតណាស់ថា សាកលភាវូបនីយកម្ម និងភាពជឿនលឿននៃបច្ចេកវិទ្យាបានបង្កើននូវទំហំពាណិជ្ជកម្ម និងទ្រព្យធនយ៉ាងធំធេងពាសពេញពិភពលោក ប៉ុន្តែ ទន្ទឹមនឹងនេះ ប្រការនេះក៏ជាកត្តាដែលបានបង្កើននូវវិសមភាព ភាពតានតឹងសង្គម ហើយពេលខ្លះបង្កើនជម្លោះទៀតផង។ ភាពងាយរងគ្រោះទាំងនេះហើយដែលរុញច្រានអោយមានជម្លោះ និងការគម្រាមកំហែងជាច្រើនលើពិភពលោកនាពេលបច្ចុប្បន្ននេះ ។

៦. បញ្ហាភេរវកម្មគឺជាការគម្រាមកំហែងមួយនៅក្នុងចំណោមការគម្រាមកំហែងទាំងនោះដែលគ្មានប្រទេសណាមួយអាចគេចរួចឡើយ។ ដើម្បីជំនះនូវការគម្រាមកំហែងអន្តរជាតិនេះ ចាំបាច់ត្រូវការមានការប្តេជ្ញាចិត្តយ៉ាងម៉ឺងម៉ាត់ជាលក្ខណៈសកល ដើម្បីប្រឈមមុខអោយបានគ្រប់ជ្រុងជ្រោយ ចំពោះគ្រប់រូបភាពនៃកត្តាដែលបង្កនូវចលាចលទាំងនេះ ដោយចាប់ផ្តើមពីរោគសញ្ញា និងមូលហេតុដើមចមនៃភាពជ្រុលនិយម បណ្តាញអ្នកប្រយុទ្ធអន្តរជាតិ និងហិរញ្ញប្បទាន និងការគាំទ្រផ្សេងៗចំពោះអំពើភេរវកម្ម ។

៧. ឯកឧត្តមប្រធាន ខ្ញុំសូមលើកយកនូវប្រធានបទពីរដែលមានភាពប្រទាក់ក្រឡាជាមួយនឹងមូលបទនៃអង្គមហាសន្និបាតយើងឆ្នាំនេះ ។ នោះគឺរបៀបវារៈឆ្នាំ ២០៣០សម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព និងបម្រែបម្រួលអាកាសធាតុ។

៨. របៀបវារៈឆ្នាំ ២០៣០ គឺមានទំនាក់ទំនងមិនអាចកាត់ផ្តាច់បានជាមួយនឹងបញ្ហាជាច្រើនដែលបង្កភាពរង្គោះរង្គើចំពោះពិភពលោកយើងសព្វថ្ងៃនេះ ហើយក្នុងនោះបញ្ហាដែលមានភាពបន្ទាន់បំផុតនោះគឺបម្រែបម្រួលអាកាសធាតុ ដែលមិនត្រឹមតែជាបញ្ហាប្រឈមផ្ទាល់នោះទេ ប៉ុន្តែវាក៏ជាកត្តាដែលបន្ថែមបន្ទុកទៅលើបញ្ហាគម្រាមកំហែងផ្សេងៗទៀតជាច្រើន រាប់តាំងពីបញ្ហាភាពក្រីក្រ សន្តិសុខស្បៀង ទេសន្តរប្រវេសន៍ទ្រង់ទ្រាយធំ និងជម្លោះតំបន់ ។ យើងមានទស្សនៈថា បញ្ហាបម្រែបម្រួលអាកាសធាតុគឺជាបញ្ហាសន្តិសុខមនុស្សជាតិ ដែលជាកត្តាគម្រាមកំហែងយ៉ាងធ្ងន់ធ្ងរ និងពុំធ្លាប់មានចំពោះសន្តិភាព និងសន្តិសុខសកល ។

៩. កម្ពុជាជារឿយៗតែងតែស្ថិតក្នុងចំណោម ១០ ប្រទេសដែលងាយរងគ្រោះបំផុតលើពិភពលោកពីអាកាសធាតុអាក្រក់ដែលបំផ្លាញហេដ្ឋារចនាសម្ព័ន្ធ ប៉ះពាល់ធ្ងន់ធ្ងរដល់កសិកម្ម បង្អាក់នូវសកម្មភាពសេដ្ឋកិច្ច និងសេវាកម្មដែលមានសារៈសំខាន់សម្រាប់ក្រុមប្រជាជនដែលងាយរងគ្រោះ។ ថ្វីត្បិតតែការចូលរួមចំណែករបស់យើងចំពោះ

បញ្ហាបម្រែបម្រួលអាកាសធាតុពុំមានអ្វីជាដុំកំភួន ហើយធនធានក្នុងប្រទេសរបស់យើងនៅមានកម្រិតយ៉ាងណាក្តី ក៏យើងបានបង្ហាញនូវប្តេជ្ញាចិត្តយ៉ាងច្បាស់លាស់ចំពោះការអភិវឌ្ឍដែលបញ្ចេញកាបូនទាប និងត្រៀមជាស្រេចក្នុងការបង្កើតភាពជាដៃគូនានាជាមួយបណ្តាប្រទេសជឿនលឿនដែលមានការប្តេជ្ញាចិត្តក្នុងការដោះស្រាយបញ្ហាប្រឈមដ៏ធំធេងនេះ ក្នុងឆន្ទៈសហការ និងសមធម៌ ។

១០. ខ្ញុំកត់សំគាល់ដោយក្តីសោមនស្សដែលកិច្ចព្រមព្រៀងទីក្រុងប៉ារីសស្តីពីអាកាសធាតុបានទទួលស្គាល់គោលការណ៍ "ការទទួលខុសត្រូវរួម តែមានកម្រិតផ្សេងគ្នា" ពោលគឺអាស្រ័យលើសមត្ថភាព និងស្ថានភាពផ្សេងៗគ្នានៃប្រជាជាតិនីមួយៗ ។

១១. ពិតណាស់ថា របៀបវារៈឆ្នាំ ២០៣០ គឺជារបៀបវារៈប្រកបដោយមហិច្ឆតាខ្ពស់សម្រាប់មនុស្សជាតិ ប៉ុន្តែ វាគឺជារបៀបវារៈដើម្បីសាកលភាវូបនីយកម្មប្រកបដោយសមធម៌។ ជាងពីរទសវត្សរ៍កន្លងមកនេះ កម្ពុជាបានបង្ហាញនូវការប្តេជ្ញាចិត្តរបស់ខ្លួនចំពោះការអភិវឌ្ឍប្រកបដោយចីរភាព។ ជាក់ស្តែង គោលដៅរបស់យើងក្នុងការកាត់បន្ថយអត្រាភាពក្រីក្រអោយធ្លាក់មកនៅកម្រិត ១៩,៥% ត្រឹមឆ្នាំ ២០១៥ បានសម្រេចដោយជោគជ័យមុនផែនការ។ យើងបានទទួលរង្វាន់ពីអង្គការសហប្រជាជាតិចំពោះការកាត់បន្ថយអត្រានៃភាពអត់ឃ្លានជាងពាក់កណ្តាល មុនពេលកំណត់ ។ កម្ពុជាក៏ជាប្រទេសឈានមុខគេទាំង ៧ លើពិភពលោកក្នុងការកែលំអសន្ទស្សន៍អភិវឌ្ឍន៍មនុស្សក្នុងចន្លោះឆ្នាំ ១៩៩០ ដល់ឆ្នាំ ២០១៥ ។

១២. ឯកឧត្តមប្រធាន ឯកឧត្តមលោកជំទាវ លោក លោកស្រី។ នៅពេលដែលយើងនិយាយពីបញ្ហាសន្តិភាព និងសន្តិសុខ កម្ពុជាមានមោទនភាពជាខ្លាំងចំពោះការប្តេជ្ញាចិត្តឥតងាករេរបស់ខ្លួនក្នុងកិច្ចខិតខំប្រឹងប្រែងរក្សាសន្តិភាពក្នុងក្របខ័ណ្ឌអង្គការសហប្រជាជាតិ ។ កាលពីជាងពីរទសវត្សរ៍មុន កម្ពុជាបានទទួលកងមួកខៀវរបស់អង្គការសហប្រជាជាតិក្នុងបេសកកម្មរក្សាសន្តិភាពនៅកម្ពុជា។ ចាប់តាំងពីឆ្នាំ ២០០៦ កម្ពុជាបានបញ្ជូនកងកំលាំងជាង ៤៧០០នាក់ ដើម្បីចូលរួមបេសកកម្មរក្សាសន្តិភាពនេះប្រកបដោយជោគជ័យធំធេង និងមានការកោតសរសើរ នៅក្នុងបណ្តាប្រទេសមួយចំនួនដែលជាចំណុចក្តៅនៅលើពិភពលោក ដូចជាស៊ូដង់ ស៊ូដង់ខាងត្បូង លីបង់ សាធារណរដ្ឋអាហ្វ្រិកកណ្តាល ឆាដ ស៊ីរី និងម៉ាលី ។

១៣. ដូចដែលយើងបានដឹងហើយថា ប្រតិបត្តិការរក្សាសន្តិភាពរមែងតែងមានហានិភ័យសន្តិសុខ ។ កងរក្សាសន្តិភាពនៅតែបន្តទទួលរងការវាយប្រហារពីក្រុមប្រដាប់អាវុធ ហើយក៏មានការកើនឡើងការវាយប្រហារពីភេរវករផងដែរ ។ កាលពីខែឧសភា កន្លងទៅនេះ ការវាយឆ្មក់របស់ក្រុមឧទ្ទាមនៅសាធារណរដ្ឋអាហ្វ្រិកកណ្តាលបានសម្លាប់និងធ្វើអោយរបួសកងរក្សាសន្តិភាពរបស់កម្ពុជា ។ ចូរយើងទាំងអស់គ្នាសំដែងនូវ

សេចក្តីដឹងគុណចំពោះអ្នកដែលបានពលីជីវិតក្នុងបេសកកម្មក្រោមទង់អង្គការសហប្រជាជាតិ និងរំលឹកពីទទួលស្គាល់របស់យើងចំពោះការចូលរួមចំណែករបស់ពួកគេក្នុងការកែប្រែប្រទេសជាច្រើនចេញពីសមរភូមិប្រយុទ្ធ ទៅជាប្រទេសមានសន្តិភាព។

១៤. ឯកឧត្តមប្រធាន នៅពេលនេះ ខ្ញុំសូមលើកឡើងនូវបញ្ហាសិទ្ធិមនុស្ស និងបញ្ហាលទ្ធិប្រជាធិបតេយ្យ ពីព្រោះថា ជារឿយៗ ប្រទេសកម្ពុជាបានក្លាយជាផ្ទាំងស៊ីបរបស់ប្រទេសមួយចំនួន ស្ថាប័នមួយចំនួននៃអង្គការសហប្រជាជាតិ ព្រមទាំងអង្គការក្រៅរដ្ឋាភិបាលអន្តរជាតិមួយចំនួនដែលសកម្មក្នុងវិស័យទាំងនេះ ។

១៥. ខ្ញុំសូមរំលឹកថា ប្រទេសកម្ពុជាប្រកាន់ខ្ជាប់នូវគោលការណ៍ជាសកល នៃការគោរពសិទ្ធិមនុស្សជាមូលដ្ឋាន និងទទួលស្គាល់ថា មិនមានភាពមិនសមស្របរវាងការគោរពអធិបតេយ្យភាពជាតិដូចដែលមានចែងក្នុងធម្មនុញ្ញអង្គការសហប្រជាជាតិ ជាមួយនឹងការសង្កេតការណ៍របស់អន្តរជាតិទៅលើការអនុវត្តសិទ្ធិទាំងនោះ ។ ប៉ុន្តែជាលក្ខខណ្ឌចាំបាច់គឺ ការសង្កេតការណ៍នេះ ត្រូវមានភាពមិនលំអៀង ត្រូវគិតគូរគ្រប់អង្គហេតុទាំងអស់ដែលពន្យល់ពីសភាពការណ៍ ដោយមិនត្រូវមានបុរេវិនិច្ឆ័យពីសំណាក់អ្នកសង្កេតការណ៍ ចំពោះអាជ្ញាធរដែលប្រសូត្រចេញដោយស្របច្បាប់តាមបែបប្រជាធិបតេយ្យឡើយ ។

១៦. ប៉ុន្តែ តើអ្វីទៅដែលជាការពិតនោះ? ខ្ញុំសូមនិយាយអោយចំចំណុចតែម្តង៖ ការវាយតម្លៃលើស្ថានភាពសិទ្ធិមនុស្ស គឺប្រែប្រួលទៅតាមកាលានុវត្តភាពនយោបាយរបស់មហាអំណាចធំៗមួយចំនួន។ វាក៏ជាឥរិយាបទដូចគ្នានេះដែរ ចំពោះអង្គការក្រៅរដ្ឋាភិបាលអន្តរជាតិធំៗមួយចំនួន ដែលមិនប្រកាន់អព្យាក្រឹត្យភាពផ្នែកនយោបាយ។

១៧. គេលើកឡើងពីបញ្ហាសិទ្ធិមនុស្ស និងបញ្ហាប្រជាធិបតេយ្យតែនៅពេលណាដែលតំលៃនេះម្រើឲ្យផលប្រយោជន៍ជាក់ស្តែងរបស់មហាអំណាចធំៗមួយចំនួន ដោយយោងតាមកាលានុវត្តភាពនៃពេលវេលា ។ បើគ្មានផលប្រយោជន៍ទេ គឺគេរក្សាភាពស្ងប់ស្ងៀម ។ ជាញឹកញាប់ ភាពស្ងប់ស្ងាត់ គឺស្មើនឹងការឃុបឃិតគ្នា ។

១៨. ប្រទេសកម្ពុជាធ្លាប់បានរងគ្រោះដោយសារការប្រើបញ្ហាសិទ្ធិមនុស្ស និងលទ្ធិប្រជាធិបតេយ្យជាឧបករណ៍នយោបាយ អស់រយៈពេលជាង១២ឆ្នាំ ដែលអំឡុងពេលនោះ អត្ថិភាពនៃឧក្រិដ្ឋកម្មដ៏អាក្រក់បំផុតនៃការសម្លាប់រង្គាល ត្រូវមិនត្រូវបានទទួលស្គាល់ដោយសហគមន៍អន្តរជាតិ ។ សម្រាប់អ្នកនៅរស់រានមានជីវិតពីរបប ប៉ុល ពត វាពិតជាគួរអោយឈឺចាប់ និងគួរអោយរន្ធត់ នៅពេលដែលឮអ្នករាយការណ៍ពិសេសទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា ចាត់ទុកឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តដោយរបបនេះ ត្រឹមជា "បញ្ហាលំបាក" ប៉ុណ្ណោះ។

១៩. រាជរដ្ឋាភិបាលកម្ពុជាជាគោលដៅនៃការរិះគន់ឥតឈប់ឈរ ដែលត្រូវបានធ្វើឡើងដោយយោងតាមតែរបាយការណ៍តែមួយជ្រុង និងលំអៀង។ របាយការណ៍ទាំងនេះតែងតែបន្ទោសរាជរដ្ឋាភិបាល និងលើកតម្កើងក្រុមប្រឆាំង ថាជាអ្នកបូជាក្នុងបុព្វហេតុលទ្ធិប្រជាធិបតេយ្យ និងសិទ្ធិមនុស្ស ។ របាយការណ៍ទាំងនេះ ជានិច្ចកាល និងជាទូទៅត្រូវបានធ្វើឡើងដើម្បីដាក់បន្ទុកលើរាជរដ្ឋាភិបាល ។ រីឯឥរិយាបថខុសឆ្គង និងខុសច្បាប់របស់ក្រុមប្រឆាំងមិនដែលត្រូវបានលើកឡើងទាល់តែសោះ ឬក៏បានលើកឡើងដោយកម្រ ។

២០.តើប្រទេសណាមួយដែលមានវត្តមាននៅក្នុងមហាសន្និបាតនេះ នឹងមិនចាត់ការអ្វីសោះចំពោះតំណាងរាស្ត្រនៃគណបក្សប្រឆាំង ដែលញុះញង់ឲ្យប្រជាជនដកបង្គោលព្រំដែន បញ្ឆេះកំហឹងដោយការញុះញង់ រើសអើងពូជសាសន៍ ការបោះពុម្ពនូវសន្ធិសញ្ញាក្លែងក្លាយ និងផែនទីក្លែងក្លាយ ដើម្បីឲ្យប្រជារាស្ត្រទូទៅយល់ច្រលំថា ទឹកដីកម្ពុជាមួយផ្នែកត្រូវបានទន្ទ្រានកាន់កាប់ដោយប្រទេសជិតខាងនោះ? តើប្រទេសណាដែលអនុញ្ញាតឱ្យមានការបរិហារកេរ្តិ៍ និងមួលបង្កាច់? នៅគ្រប់ទីកន្លែងក្នុងពិភពលោក ការអំពាវនាវអោយមានការស្អប់ខ្ពើមជាតិសាសន៍ និងសារដែលគាំទ្រ អោយមានការរើសអើងពូជសាសន៍របស់ក្រុមស្តាំនិយមជ្រុល តែងតែត្រូវបានថ្កោលទោសយ៉ាងធ្ងន់ធ្ងរ ហើយជួនកាលថែមទាំងត្រូវផ្តន្ទាទោសទៀតផង ដូចជាអ្វីដែលយើងបានឃើញនៅក្នុងព្រឹត្តិការណ៍ក្នុងក្រុង Charlottesville ថ្មីៗនេះ ។ ផ្ទុយទៅវិញ ភាសាបែបនេះដែលត្រូវបានប្រើប្រាស់ជារៀងរាល់ថ្ងៃដោយបក្សប្រឆាំងកម្ពុជា បែរជាមិនដែលត្រូវបានគេថ្កោលទោសទៅវិញ ហើយក៏មិនដែលត្រូវបានលើកឡើងដោយអង្គការក្រៅរដ្ឋាភិបាល និងអ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជាឡើយ ។

២១. ការរិះគន់ថ្មីៗបំផុតប្រឆាំងនឹងរាជរដ្ឋាភិបាលកម្ពុជាគឺពាក់ព័ន្ធនឹងការបណ្តេញវិទ្យាស្ថានមួយមកពីគណបក្សនយោបាយបរទេស ដែលជ្រកក្រោមស្លាកនៃការបណ្តុះបណ្តាលលទ្ធិប្រជាធិបតេយ្យ តែការពិតបានគាំទ្រគណបក្សប្រឆាំងដោយពេញទំហឹង និងបានរំលោភបំពានច្បាប់ ការបិទអាជីវកម្មរបស់សហគ្រាសសារព័ត៌មានបរទេសមួយដែលបដិសេធមិនគោរពច្បាប់ពន្ធដារ រួមទាំងការចាប់ខ្លួនប្រធានគណបក្សប្រឆាំង ដែលបានសារភាពដោយខ្លួនឯង នៅក្នុងខ្សែវីដេអូថាខ្លួនជាឧបករណ៍របស់មហាអំណាចមួយ ដើម្បីផ្តួលរំលំរាជរដ្ឋាភិបាល។ ខ្ញុំសូមសួរអស់លោក លោកស្រី ដែលជាតំណាងប្រជាជាតិនីមួយៗថា តើប្រទេសណាដែលអាចអន់ឱនឲ្យអាកប្បកិរិយារដ្ឋាភិបាលបរទេសបែបនេះបាននោះ? យើងបានចាត់ការដោយយោងតាមច្បាប់របស់ប្រទេសយើងយ៉ាងត្រឹមត្រូវនិងច្បាស់លាស់ ហើយមិនមែនជាការអនុវត្តតាមទំនើងចិត្តដូចអ្វីដែលគេបានចោទប្រកាន់នោះឡើយ ។

២២. ប្រវត្តិសាស្ត្ររបស់ប្រទេសខ្ញុំផ្តល់មេរៀនសំខាន់មួយដល់យើង ៖ នៅពេលមហាអំណាចលោកខាងលិចមួយចំនួន បានបង្ខំឱ្យកម្ពុជាដើរតាមផ្លូវដែលពួកគេកំណត់នោះ ប្រទេសកម្ពុជាតែងជួបនឹងគ្រោះមហន្តរាយ ដែលនាំដល់សោកនាដកម្មដ៏អាក្រក់បំផុតមួយនៅសតវត្សកន្លងមក ។

២៣.សន្តិភាពនៅកម្ពុជា ត្រូវបានរាជរដ្ឋាភិបាលកម្ពុជាជាអ្នកផ្តើមយកបានជាស្ថាពរ នៅក្នុងឆ្នាំ១៩៩៨ ក្រោមការដឹកនាំដ៏ខ្ពង់ខ្ពស់របស់ សម្តេចតេជោនាយករដ្ឋមន្ត្រី **ហ៊ុន សែន** និងការ អនុវត្តនូវវិធីសាស្ត្ររបស់យើងផ្ទាល់។ នេះគឺជាការបង្ហាញឲ្យឃើញយ៉ាងច្បាស់ថា ផ្លូវខ្លះដែលត្រូវបានដាក់បង្ខំពីមជ្ឈដ្ឋានខាងក្រៅ ច្រើនតែបង្កជាបញ្ហាជាជាងដំណោះស្រាយ ។

២៤. សព្វថ្ងៃនេះ គេចោទប្រកាន់យើងថាបានធ្វើឲ្យប៉ះពាល់ដល់លទ្ធិប្រជាធិបតេយ្យ ដោយសារតែយើងអនុវត្តតាមច្បាប់របស់យើងដែលមានស្រាប់ ដោយប្តឹង និងផ្តន្ទាទោសអ្នកដែលបំពានច្បាប់ទាំងនោះ ។ អ្នកដែលរិះគន់យើង ដែលគំរាមកំហែងយើង មិនគិតគូរពីបទឧក្រិដ្ឋនានា ដែលត្រូវបានប្រព្រឹត្តដោយអ្នកដែលពួកគេកំពុងការពារនោះឡើយ ។

២៥. ឯកឧត្តមប្រធាន ឯកឧត្តម អគ្គលេខាធិការ ទន្ទឹមនឹងការទទួលស្គាល់ដោយសេចក្តីដឹងគុណយ៉ាងស្មោះស្ម័គ្រចំពោះការចូលរួមចំណែកជាវិជ្ជមាន និងមានសារៈសំខាន់ដែលបណ្តាប្រទេសជាច្រើនបានផ្តល់ចំពោះសន្តិភាព និងការអភិវឌ្ឍសេដ្ឋកិច្ចរបស់ប្រទេសយើងខ្ញុំ ខ្ញុំសូមបញ្ចប់ដោយបញ្ជាក់អះអាងថា ទ្រឹស្តីរបស់រដ្ឋាភិបាលមួយចំនួនស្តីពីសិទ្ធិមនុស្ស និងលទ្ធិប្រជាធិបតេយ្យនឹងមានលក្ខណៈសមហេតុផល ព្រមទាំងគួរអោយជឿទុកចិត្តបាន លុះត្រាតែប្រទេសទាំងនេះអនុវត្តទ្រឹស្តីនោះចំពោះប្រទេសខ្លួន ព្រមទាំងធ្វើការវាយតំលៃ រិះគន់ និងថ្កោលទោសដោយស្មើគ្នាចំពោះអ្នកដទៃ ។

ខ្ញុំសូមអរគុណ ។

----------------